# ការសម្ភាសរបស់អ៊ុំស្រី ចាន់ ឆេន

**កៈ អ្នកសម្ភាសឈ្មោះ លន់ មុណាក់** **ខៈ អ្នកត្រូវគេសម្ភាសឈ្មោះ ចាន់ ឆេន**

## ពត័មានសង្ខេបរបស់អ៊ុំស្រី ចាន់ឆេន

កៈ អ៊ុំស្រី ចាន់ឆេនៈ មានទីលំនៅបច្ចុប្បន្ននៅខេត្តបាត់ដំបងប្រទេសកម្ពុជា នៅភូមិអូរដំបង ឃុំអូរដំបង ២ ស្រុកសង្កែ ខេត្តបាត់ដំបង។ ឥឡូវនេះអ៊ុំមានអាយុ ៥៩ឆ្នាំ។ ហើយអ៊ុំបានកើតនៅឆ្នាំ ១៩៦០ ខែ ០៣ នៅខេត្តកំពង់ធំ។ ហើយអ៊ុំបានរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ ២០០៧ ខែ ០៨ ហើយក្រោយពីរៀបការអ៊ុំមានកូនស្រីម្នាក់ ហើយសព្វថ្ងៃនេះគាត់រស់នៅស្រុកអាមេរិច។ នៅក្នុងគ្រុមគ្រួសាររបស់អ៊ុំស្រីអ៊ុំមានបងប្អូនបួននាក់ ហើយអ៊ុំជាកូនច្បង។ សព្វថ្ងៃនេះអ៊ុំជាស្រ្តីមេម៉ាយ។

កៈ អញ្ចឹងជាដំបូងខ្ញុំសូមជំរាបសួរអ៊ុំ។

ខៈ ចាសជំរាបសួរ។

កៈ ខ្ញុំមកពីខាងសាលាសាកលវិទ្យាល័យមួយនៅសហរដ្ឋអាមេរិចហើយគេបានអញ្ជើញខ្ញុំមកថ្ងៃនេះដើម្បីធ្វើការសម្ភាសជីវប្រវត្តិរបស់ប្រជាជនខ្មែរកាលពីនៅសម័យប៉ុលពតហាអ៊ុំ។

ខៈ ចាស!

កៈ ចាស! អញ្ចឹងខ្ញុំមកថ្ងៃនេះដើម្បីធ្វើការសម្ភាសអ៊ុំពីមួយនឹងតើអ៊ុំបានឈ្លងកាត់នូវការលំបាកអ្វីខ្លះនៅក្នុងជីវិតរបស់អ៊ុំហាស់!។

ខៈ ចាស!

កៈ អញ្ចឹងខ្ញុំអ្នកធ្វើការសម្ភាសនៅថ្ងៃនេះនាថខ្ញុំ លន់ មុណាក់។ ហើយថ្ងៃនេះជាថ្ងៃទី ២៩ ខែ ០៥ ឆ្នាំ ២០២០។ អញ្ចឹងតើអ៊ុំស្រីមានឈ្មោះអ្វីដែល?

ខៈ ខ្ញុំឈ្មោះ ចាន់ ឆេន។

កៈ ចាន់ ធេន?

ខៈ ចាស!

កៈ នឹងជាឈ្មោះនៅក្នុងអត្តសញ្ញាណប័ណ្ណម៉ងហីអ៊ុំ?

ខៈ ចាស! នឹងហើយ។

កៈ អញ្ចឹងតើអ៊ុំមានឈ្មោះដែលគេហៅក្រៅអ្វីផ្សេងពីនឹងទៀតដែឡឬអត់?

ខ: ឈ្មោះ ធឹង។

កៈ អ៊ុំ ធឹង?

ខៈ ចាស!

កៈ អរ! តែមួយនឹងទេន៍អ៊ុំ?

ខៈ ចាសនឹងហើយ។

កៈ ចាសអ៊ុំ!! អញ្ចឹងតើឥឡូវនេះអ៊ុំមានអាយុប៉ុន្មានហើយ?

ខៈ អ៊ុំ ៥៩។

កៈ ៥៩?

ខៈ ចាសនឹងហើយ។

កៈ អញ្ចឹងតើអ៊ុំមានចាំថ្ងៃខែឆ្នាំអ៊ុំកើតដែលឬអត់?

ខៈ ឆ្នាំ ១៩៦០។

កៈ ១៩៦០ ហីអ៊ុំ?

ខៈ ចាស!

កៈ ចុះតើអ៊ុំមានចាំខែដែលឬទេ?

ខ៖ ខែ ០៣។ ខែដាច់ខែលង្គុនខែបីហើយនេះ?

ក៖ ចាស! ខែបី។

ខ៖ ចាស! មិនដឹងថាថ្ងៃទីប៉ុន្មានអត់ដឹង។

ក៖ ចាសអ៊ុំ! អញ្ចឹងតើអ៊ុំមានចាំស្រុកកំណើតដែលអ៊ុំបានកើតដែលឬអត់តើអ៊ុំកើតនៅណា?

ខ៖ កើតនៅកំពង់ធំ, កើតនៅកំពង់ទឹកអណ្ដូង កំពង់ធំ។

ក៖ ចាសអ៊ុំ។

ខ៖ ខេត្ត កំពង់ធំ។

ក៖ ចាសអ៊ុំ!។ អញ្ចឹងអ៊ុំរស់នៅសព្វថ្ងៃនេះអ៊ុំរស់នៅបាត់ដំបង?

ខ៖ ចាសរស់នៅបាត់ដំបង។

ក៖ ចាស! អញ្ចឹងតើអ៊ុំដូរមករស់នៅទីនេះប៉ុន្មានឆ្នាំហើយ?

ខ៖ តាំងពីឆ្នាំ ១៩៩២។

ក៖ តាំងពី ១៩៩២ មកយូរដែលហើយ។

ខ៖ ចាស! មកពីជំរុំមក ១៩៩២។

ក៖ ចាស!

ខ៖ ចាស!

ក៖ អញ្ចឹងតើអ៊ុំមានចាំ ថ្ងៃខែ ហើយនឹងឆ្នាំដែលអ៊ុំបានរៀបការទេ? តើអ៊ុំបានរៀបអាពាហ៍ពិពាហ៍នៅខែណាហើយឆ្នាំណាតើអ៊ុំមានចាំដែលឬទេ?

ខ៖ នៅឆ្នាំ ២០០៧។

ក៖ នៅឆ្នាំ ២០០៧ យើងនេះហ្នអ៊ុំ?

ខ៖ ចាស!

ក៖ អូ!!! ខែណាដែលតើអ៊ុំមានចាំអត់ឬក៏អត់ចាំទេ?

ខ៖ ខែប្រាំបី។

ក៖ ខែប្រាំបី។ អញ្ចឹងតើអ៊ុំអាចប្រាប់ពីប្រវត្តិសេហ្មារបស់អ៊ុំខ្លះបានទេ?

ខ៖ ហាហា!

ក៖

ខ៖ និយាយទាំងអស់ក៏បានដែល។  តើអ៊ុំបានជួបគ្នាដោយរបៀបណាហើយតាមរយៈអ្នកណាគេដែល?

ខ៖ ជួបគ្នាដោយចៃដន្យ, បានប្ដីបារាំនឹងហាស់។ បានប្ដីទាហាន។

ក៖ ចាស!

ខ៖ ពេលដែលអ៊ុំទៅនៅដល់ជំរុះ ហើយអ៊ុំបានមកវិញនៅឆ្នាំ១៩៩២។

ក៖ ចាស! អញ្ចឹងអ៊ុំបានស្គាល់គ្នាពេលដែលអ៊ុំនៅជំរុំ?

ខ៖ ចាសនឹងហើយ។ ស្គាល់តាំងពីស្រុកខ្មែរយើងទៅនឹងហាស់។

ក៖ ចាសអ៊ុំ! អញ្ចឹងអ៊ុំស្គាល់គ្នា?

ខ៖ ចាស! ហើយដល់បេលចឹងទៅក៏ខ្ញុំបែកគ្នាទៅ។

ក៖ ហ៊ឹម!!

ខ៖ បែកគ្នានឹងកូនខ្ញុំនៅតូចៗដែលនឹងហាស់។

ក៖ ចាសអ៊ុំ!

ខ៖ បែកគ្នានឹងកូនខ្ញុំបានមួយខួបជាងនឹង! រស់នៅជាមួយនឹងយាយហើយនឹងរហូត យាយម៉ែចិញ្ចឹមនឹង។

កៈ ចាសអ៊ុំ!

ខៈ ហើយក៏នៅជាមួយនឹងគាត់រហូតមក។

កៈ ចាសនឹងហើយអ៊ុំ។ អញ្ចឹងតើអ៊ុំមានកូនប៉ុន្មាននាក់ដែល?

ខៈ កូនមួយ។

កៈ អញ្ចឹងតើឥឡូវនេះតើគាត់មានអាយុប៉ន្មានហើយអ៊ុំ?

ខៈ ឥឡូវនេះគាត់ ៣១ ៣២ ៣៣ហើយ។

កៈ  អូ!! គាត់ចាស់ដែលហើយ។

ខៈ ឆ្នាំ រោង។

កៈ ចាសអ៊ុំ!។

ខៈ ឥឡូវនេះវា ៣២ ៣៣ ៣៤ ហើយ។

កៈ ចាស! អញ្ចឹងតើគាត់មានគ្រួសារហើយនៅអ៊ុំ?

ខៈ មានហើយ!

កៈ ចាស!

ខៈ មានប្រពន្ធមានកូន។

កៈ ចាស! អញ្ចឹងតើឥឡូវនេះតើគាត់រស់នៅឯណាដែលអ៊ុំ?

ខៈ ឥឡូវនេះគាត់នៅក្រៅ។ នៅអាមេរិច។

កៈ នៅអាមេរិចហីអ៊ុំ?

ខៈ ចាស!

កៈ អូ!! អ៊ុំមានកូនមួយហើយបានទៅរស់នៅអាមរិចទៀត។

ខ៖ ហាហា។

ក៖ ចាស! អញ្ចឹងតើគាត់ដែលមកលេងអ៊ុំដែល?

ខ៖ អតទេ! តាំងពីគេផ្អើលកូវីតនឹងមកវាមិនដែលបានមកផង។ ពីមុខវាមក។

ក៖ ចាសអ៊ុំ! អញ្ចឹងតើកូនរបស់អ៊ុំតើគាត់មានកូនចៅប៉ុន្មាននាក់ដែល?

ខ៖ កូនមួយ។

ក៖ ចាស!

ខ៖ កូនមួយហើយ កូនស្រី។

ក៖ ចាស!

ខ៖ មួយខួបជាំងហើយ។

ក៖ អូ!! ទឹមតែកើតដែល។

ខ៖ ចាសនឹងហើយទឹមកើត។

ក៖ មួយខួបជាង វាមួយឆ្នាំជាងហើយន៍អ៊ុំ?

ខ៖ ចាសនឹងហើយ!

ក៖ ចាស! អញ្ចឹងពេលដែលអ៊ុំរៀបការនឹង,ឪពុកម្ដាយរបស់អ៊ុំជាអ្នករៀបចំអោយអ៊ុំឬក៏អ្នកណាដែលជាអ្នករៀបចំអើយអ៊ុំដែល?

ខ៖ ឪពុកម្ដាយខ្ញុំស្លដាប់តាំងពីឆ្នាំ ១៩៧៥ម្លះ។

ក៖ ចាស! អញ្ចឹងនៅក្នុងសមាជិកគ្រុមគ្រួសាររបស់អ៊ុំតើអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែល?

ខ៖ នៅណានៅ?

ក៖ បងប្អូនបង្កើត។

ខ៖ បងប្អូនបង្កើតសព្វថ្ងៃនៅបួននាក់។

ក៖ បួននាក់?

ខ៖ ចាស! ហើយប្រុសមួយស្រីបី។

ក៖ ចាស! ប្រុមួយស្រីបី! អញ្ចឹងតើអ៊ុំជាកូនទីប៉ុន្មានដែល?

ខ៖ អ៊ុំជាកូនបង។

ក៖ ចាស!

ខ៖ បងគេ។

ក៖ អញ្ចឹងតើបងប្អូនរបស់អ៊ុំឥឡូវតើពួកគាត់មានគ្រុមគ្រួសារអស់ហើយ?

ខ៖ មានអស់ហើយ។

ក៖ ចាស!!

ខ៖ ចាស!

ក៖ ចាស! អញ្ចឹងតើពួកគាត់នៅទីនេះទាំងអស់គ្នាតៀហីអ៊ុំ?

ខ៖ ចាស! នៅទីនេះទាំងអស់។ នៅជាមួយម៉ែនឹង។

ក៖ ចាស! នឹង, អញ្ចឹងម្តាយឪពុករបស់តើពួកគាត់មានឈ្មោះអ្វីដែល?

ខ៖ ឪពុកខ្ញុំឈ្មោះ យឹង ម្តាយខ្ញុំឈ្មោះ ស្រី។

ក៖ ចាសអ៊ុំ។ ស្រី?

ខ៖ ចាស!

ក៖ តើអ៊ុំមានចាំថ្ងៃកើតរបស់ពួកគាត់ដែលឬអត់ ឬក៏ទៅកន្លែងកំណើតរបស់ពួកគាត់ដែលអត់?

ខ៖ អ៊ុំមិនដែលចាំ ហើយក៏អ៊ុំមិនដែលបានសួរគាត់ផង។

កៈ ចាស! អញ្ចឹងគាត់ក៏អត់ដែលបានប្រាប់អ៊ុំដែល?

ខៈ ដឹងតែ, អ៊ុំកើតមកគាត់មកហើយអ៊ុំបានធំដឹងក្ដីមក! អ៊ុំឃើញគាត់នៅតែនឹងភូមិនឹងប៉ុនដោយ។ ភូមិទឹកអណ្ដូងនឹងប៉ុនដោយ។

កៈ ចាសអ៊ុំ!

ខៈ នឹងហើយ។ ស្រុកកំណើតនៅខេត្តកំពង់ធំ។ ពីមុនគេហៅថាពស្រុកសន្ទុកតែឥឡូវគេហៅព្រៃសំបូរវិញ។

កៈ ចាសអ៊ុំ! ស្រុកខេត្តសំបូរនៅខេត្តកំពង់ធំ?

ខៈ ចាសនឹងហើយ!។

កៈ ចាស! អញ្ចឹងតើពួកគាត់ស្លាប់អស់ហើយហីអ៊ុំ?

ខៈ នៅម្ដាយ។

កៈ អូ!!!

ខៈ ម្ដាយរបស់ខ្ញុំកាត់ អាយុ ៨៧ឆ្នាំហើយ។

កៈ ៨៧?

ខៈ ចាស!

កៈ ចុះតើឥឡូវនេះគាត់នៅជាមួយអ៊ុំឬក៏គាត់រស់នៅឯណាដែល?

ខៈ នៅជាមួយប្អូនរបស់ខ្ញ។នៅខេត្តកំពង់ធំ។

កៈ អូ!!

ខៈ នៅកំបង់ធំ។

កៈ ៨៧ឆ្នាំអាយុច្រើនដែលហើយ។

ខៈ ចាស! អាយុច្រើន។

កៈ អញ្ចឹងតើអ៊ុំមានចាំឈ្មោះជីដូនជីតារបស់អ៊ុំដែលរអត់?

ខៈ ចាំ ខាងម៉ែ។ ជីតាឈ្មោះ ចាន់។

កៈ ចាសអ៊ុំ!

ខៈ ហើយយាយឈ្មោះៈ យាយមុត។

កៈ ចាសអ៊ុំ! អញ្ចឹងតើអ៊ុំមានដឹងថាពួកគាត់កើតនៅភូមិណាហើយខេត្តណាដែលឬអត់អ៊ុំ?

ខៈ កើតនៅភូមិ, ភូមិគុកនឹងឯង គេហៅថាភូមិគុក ខេត្តកំពង់ធំ។

កៈ ចាសភូមិគុកខេត្តកំពង់ធំ។

ខៈ ចាសនឹងើហយ។

កៈ ចាស! អញ្ចឹងមានចាំអ្វីខ្លះពីជីដូនជីតារបស់អ៊ុំដែលឬទេ? ដោយសារតែឪពុករបស់អ៊ុំបានសហល្លាប់ហើយមែនទេនៅតែម្ដាយ? ដូចជាតើពួកគាត់យ៉ាងម៉េចដែលអំពីជីដូនជីតារបស់អ៊ុំហាស់ តើពួកគាំត់មានពួកគាត់អីអត់កាលនឹង?

ខៈ ខ្ញុំវាកើតមិទាន់គាត់ដែលកាលនឹង។

កៈ ចាសអ៊ុំ!។

ខៈ ប៉ន្តែជីដូនជូតាខាងម្ដាយរបស់ខ្ញុំក្រណាស់គ្មានស្អីទេ។

កៈ ចាសអ៊ុំ!

ខៈ រកតែផ្ទះនៅគ្មាន។ នៅផ្ទះខ្ទមតូចៗ។

កៈ ចាសអ៊ុំ!

ខៈ ផ្ទះប្រក់ស្បូវយើងហាស់!? ដូចផ្ទះដែលយើងធ្វើនៅខ្ទមស្រែចឹងហាស់។

កៈ ចាសអ៊ុំ!

ខៈ នឹងហើយ! នៅតាមចឹងឯង។ ពេលនេះម៉ែជីដូនបង្កើតត្រូវជាយាយរបស់អ៊ុំនឹងហាស់។

កៈ ចាសអ៊ុំ!

ខៈ អ៊ុំកើតទាន់តែពេលនឹងឯង។

កៈ ហ៊ឹម! ចុះឪពុករបស់អ៊ុំកាលដែលគាត់នៅរស់តើកាត់ធ្វើការអ្វីដែល?

ខៈ គាត់ធ្វើស្រែធ្វើចំការអោយគេ។ កាលពីនៅសង្គមអ៊ុំមិនដឹងថាគាត់បានធ្វើស្អីនោះទេ! ប៉ុន្តែពេលដែលអ៊ុំធំដឹងក្តីមកគឺអ៊ុំឃើញតែគាត់ធ្វើស្រែ។

កៈ ចាសអ៊ុំ!

ខៈ ហើយដល់ពេលជំនាន់ប៉ុលពតនឹងគេអោយគាត់មកវាលក្រោមនឹងទៅក៏ស្លាប់។ ទៅវាលក្រោមនឹងទៅគាត់ក៏ស្លាប់ណៅវាលក្រោមនឹងទៅ។ កន្លែងធ្វើការនឹង។

កៈ ចាសអ៊ុំ!

ខៈ គាត់ខូចពេលដែលគាត់មានអាយុ៧៥ឆ្នាំ។ ៧៥ពេលដែលខ្មែរក្រហមចូល។

កៈ ចាស! ខូចពេលដែលខ្មែរក្រកមចូល?

ខៈ ចាសនឹងហើយ។

កៈ មិនមែនខ្មែរក្រហមជាអ្នកសម្លាប់គាត់ណាហីអ៊ុំ?

ខៈ អត់ទេ! គាត់ឈឺរោគ។ គាត់ចុកហាស់។

កៈ ចាស!

ខៈ គាត់ចុកក្អួត។

កៈ អ!! គាត់កើតរោគចុកក្អួត?

ខៈ ចាស! រាគមូល។

កៈ ចាស!

ខ៖ ទៅក៏គាត់ស្លាប់ទៅ! អ៊ុំមិនតង់បានឃើញមុខគាត់ផង។ គាត់ស្លាប់នៅកំបង់ធំហើយអ៊ុំនីជន់បទអាល័យតែនៅធ្វើលើកប្រឡាយ, លើកដីនៅជំនាន់នឹងគេអោយលើកដីធ្វើទំនប់ហ្ន?

ក៖ ចាសអ៊ុំ។

ខ៖ នៅលើកដីលើកអីនៅនឹងទៅហើយអ៊ុំនៅនឹងទៅ។

ក៖ ចាសអ៊ុំ!

ខ៖ កាលនឹងអាយុ១៩ឆ្នាំ។ ហើយគេបញ្ចូលធ្វើកងនារីចល័តហើយនឹង។ មិនមែននៅកុមារអី។

ក៖ ចាសអ៊ុំ!

ខ៖ គេអាយុតំណាលយើងដែលតែតែនៅកុមារ។ តែយើងវិញគេបញ្ចូលនារីចល័ត។ ចុះកាលនឹងមាឌយើងមាឌយើងវាតូចជាងគេហ្ន។

ក៖ ចាស!

ខ៖ ហាហា!

ក៖ ចឹងកាលនឹងមាឌអ៊ុំតូចជាងគេហ្ន?

ខ៖ ចាសតូចជាងគេ! ១៩ឆ្នាំ ប្រហែលគេ១៧ ១៨ឆ្នាំ មានអី ហាហា។ គេបញ្ចូលនារីផ្លុក។

ក៖ ចាស!

ខ៖ ហើយមានអី លើកដីវាស់ម៉ែ្រត ពីម៉ែ្រតម្នាក់ឯង។ ខ្ចងមួយម៉ែ្រតហើយបណ្តោយពីរម៉ែ្រតម្នាក់ឯងចង់ដាច់ខ្យល់។ នៅអាយុប៉ុននឹង។

ក៖ ចាសអ៊ុំ!

ខ៖ គេថាលើកអោយរួច។ ហើយទំរាំតែលើករួចប្រលុប។

ក៖ ចាសអ៊ុំ!

ខ៖ ចាស!

កៈ នឹង! ដោយសារតែអ៊ុំកើតទាន់សម័យប៉ុលពតនឹងអ៊ុំ មានអាយុប៉ុន្មានមិញ? អាយុ១៨ឆ្នាំ?

ខៈ អាយុ១៨ឆ្នាំ។ រហូតដល់អាយុយួនចូល ១៩។ យួនចូល ១៩ ដល់សន្តិភាពវិញអាយុ១៩។

កៈ ចាសអ៊ុំ!

ខៈ ពេលរំដោះបានហាស់?

កៈ ចាស!

ខៈ នឹងហើយ! ៧៩។ យួនរំដោះ។

កៈ ចាស! អញ្ចឹងតើពេលនឹងអ៊ុំបានជួបនៅការលំបាកអ្វីខ្លះតើអ៊ុំអាចប្រាប់ខ្ញុំអោយបានលំអិតតិចតើបានទេ?

ខៈ លំបាកមានតែ លើកដី គែដាក់ម៉ែ្រតគីបទៅ។ រ៉ែកដីទៅ រត់ រ៉ែកឡើងពីប្រឡាយទៅ។ គេអោយយើងជីកប្រឡាយខ្នងប៉ុន្មាន? ដប់ម៉ែ្រតអីអញ្ចឹងទៅ, ជីកបាតប្រឡាយទទឹងប៉ុន្មានាបាតក្រោមប្រាំមួយម៉ែ្រតអីទៅ។ ខ្នងលើដប់ម៉ែ្រតជាងហើយ។

កៈ ចាស!

ខៈ គែវាស់ម៉ែ្រតអោយយើងជីកដីទៅ។

កៈ ចាសអ៊ុំ!

ខៈ ហើយកាលនៅជំនាន់នោះយើងមិនដឹងថាវាទៅជាំយ៉ុាំងណាអីយ៉ាង ណា។ យើងដឹងតែថាពីសប្បាយរត់ទៅ។ ព្រោះអីក្មេងអត់ដឹងខ្យល់អ្នកណាចង់យកទៅសម្លាប់នៅឯងណាក៏អត់ដឹងខ្យល់អីដែល។

កៈ ចាសអ៊ុំ។

ខៈ យើងនៅក្មេងយើងមិនដឹងថាគេយកទោសពៃអីមិនដឹងឃើញតេគេដឹកចាស់ៗអីទៅមិនដឹង។ យើងកាលនឹងនៅក្មេងៗ ១៤ ១៥ ឆ្នាំអីកាលនឹងក្មេងៗគ្មានដឹងស្អីទេ។

កៈ ចាសអ៊ុំ។

ខ៖ ចេះតែសប្បាយទៅ។

ក៖ ចាស!

ខ៖ អូ! ឃើញគេរែកដីឯងសប្បាយនឹងគេទៅ! ប៉ុន្តែមិនដឹងថាគេរែកយ៉ាងណាអីអត់ដឹងខ្យល់។

ក៖ ចាសអ៊ុំ!។

ខ៖ ចេះតែរែករត់នឹងគេទៅ។ គេរត់ក៏ចេះតែរត់នឹងគេទៅ គែធ្វើអីធ្វើនឹងគេទៅ។ យប់ឡើងដេកនឹងតែចឹងទៅ។ ហើយបើថាឈឺចង់ហែងចាក់ថ្នាំដបប៉ុននេះ! បូមថ្នាំដូចដបយើងដូចដបសារ៉ូមចឹងហាស់។ ចាក់។

ក៖ ចាសអ៊ុំ!

ខ៖ មួយម្ជុលនឹងចាក់ពីរបីនាក់។ ហាហា!

ក៖ ចាសអ៊ុំ! ហាហា! មួយម្ជុលហ្ស?

ខ៖ ចាសនឹងហើយ! ចាក់ហើយទៅសំលៀង, ហើយមិនមែនដូចយលងសព្វថ្ងៃចាក់ហើយចោលចាក់ហើយចោលណាព្រះហើយ។ ចាក់មួយម្ជុលនឹងពីរបីនាក់ហើយចាក់នេះផងចាក់នោះផង។

ក៖ ចាសហាហា!

ខ៖ ហាហា!

ក៖ នឹង។

ខ៖ ហើយខយប់ម៉ោងបីអីនឹង ផ្លុំកញ្ចែរច្រែតអ្នកណាក្រោកទាន់ទាន់ហើយអ្នកណាក្រោកមិនទាន់ក៏មិនទាន់។ ទៅស្ទូងហើយទឹកត្រឹមៗនេះ ហើយអោនស្ទូងទៅ ឈ្លើងទាមហែងត្រយ៉ោង។

ក៖ អឺរ!

ខ៖ ចុះកាលជំនាន់នឹងមិនទាន់នេះឯណា! ពេលឈ្លើងទាមលាត់ហែង(សំពត់) ប៉ះឈ្លើងបេញ។

ក៖ ហាហា!

ខ៖ ហាហា! ហើយនៅកាលនោះអង្គុយនោមនៅលើភ្លឺស្រែ។

ក៖ ចាស! កាលនឹងធ្វើការដល់យប់ហីអ៊ុំ?

ខ៖ ក្រោកមកម៉ោងបីហាស់ មកស្ទូងហាស់។

ក៖ អូ!! មើលអីឃើញដែលអ៊ុំ?

ខ៖ អើ!! មិនដឹងមើលអីឃើញមិនឃើញ! ជួយមិនបានទេ។ មកអង្គុយងោកនៅនឹងភ្លឺស្រែសិនទៅ។

ក៖ ហាហា!

ខ៖ អើ!

ក៖ តែសំខាន់តើគេអោយទៅដល់នោះម៉ោងប៉ុន្មាន?

ខ៖ គេអោយទៅដល់នោះ, ម៉ោងនឹង។ បើទៅមិនទាន់ម៉ោងនឹងទេ។ គេវាស់អោយថែមពីរម៉្រែតនឹថលើស។ គេវាស់ពីរម៉្រែតអោយយើងយើងស្ទូងបណ្តោយមួយរយ។

ក៖ ចាស!

ខ៖ ពីរម៉្រែតមួយនាកើនឹង, ហើយបើសិនជាយើងទៅមិនទាន់ទេ គេវាស់ថែមអោយយើងពីម៉្រែតទៀតទៅ។

ក៖ ពីរម៉្រែតទៀតទៅ?

ខ៖ ចាស! ហើយម្លោះហើយសុខចិត្តទៅអង្គុយងោកនៅនឹងភ្លឺស្រែនឹងទៅ។

ក៖ ទៅដេកនឹងស្រែ។

ខ៖ ចាស! ងោកសិនទៅទៅរាំបានចុះស្ទួង។

ក៖ ចាសហាហា!

ខ៖ ហើយមួយថ្ងៃពីរម៉ែ្រតនឹងបណ្តោយមួយរយម៉ែ្រតទំរាំតែហើយនឹងចង់ដាច់ខ្យល់។ បណ្តោយមួយរយម៉ែ្រតហើយទទឹងពីរម៉ែ្រតស្ទួងទៅ។

ក៖ អូ!!

ខ៖ ប៉ុន្តែហើយ។

ក៖ អូបានហើយទៀតអ៊ុំ?

ខ៖ ហើយ! ហើយ នៅតែហើយ។

ក៖ ចាស!

ខ៖ បើសិនជាមិនហើយគេថែមទៀត។

ក៖ អញ្ចឹងមានន័យថាទោសបីជាអស់កម្លាំងយ៉ាងណាក៏ត្រូវតែខំធ្វើវាអោយហើយមែនទេអ៊ុំ?

ខ៖ ចុះយើងនៅក្មេងយើងអត់ហាត់ទេ។ ហើយទោះបីជាហាត់ប៉ុនណាក៏យើងទាំដែល។ តែបើដូចសព្វថ្ងៃនេះទៅមិនរួចទេ។

ក៖ ចាសអ៊ុំ!

ខ៖ ចាសនឹងហើយ! ដូចសព្វថ្ងៃទៅលេងរួចហើយរវល់នឹងស្រែនឹងឯង។

ក៖ ចាស! អញ្ចឹងកាលនឹងគេអោយអ៊ុំញាំម៉េចដែលឆ្អែតដែលឬអត់?

ខ៖ ញាំបបរ, ជួនណាទៅបបរខាប់អីចឹងទៅ។ គេបបរគោកហាស់ ខាងអ៊ុំឯនោះហាស់?

ក៖ ចាសអ៊ុំ។

ខ៖ បបរគោកទទេ។ និយាយត្រង់បបរគោកយើងនិយាយតាមការពិត បបរគោកទៅ។

ក៖ ចាសចា!។

ខ៖ ជួនកាលបាយខ្លះទៅ! បើតំបន់គេទាបៗគេបបរវ៉ារចឹងហាស់។

ក៖ ចាសអ៊ុំ!

ខ៖ ប៉ុន្តែខាងនោះគេបបរចឹងគេវាល់ដាក់មួយចានមួយចានម្នាក់ចឹងទៅ។

ក៖ ចាសអ៊ុំ! អូ!! បានបបរគោកញ៉ាំ។

ខ៖ ចាស!

ក៖ ព្រោះអីអ្នកខ្លះគាត់ញ៉ាំបានតែទឹកបបរហើយនឹងអង្ករពីរបីគ្រាប់។

ខ៖ ហ៊ឹម!

ក៖ អញ្ចឹងមួយនឹងម៉េចអ៊ុំ?តាមតំបន់ឬក៏យ៉ាងម៉ែច?

ខ៖ តាមតំបន់។

ក៖ អូ!!!

ខ៖ គេបបរអោយយើងធ្វើការមែន, តែគែបបរទៅវាល់មួយចានមួយចានដាក់អោយយើងតំរៀបដង្ហែរគ្នាចឹងទៅណាស់។

ក៖ ចាសអ៊ុំ!

ខ៖ ហើយយើងមកពីធ្វើការចឹងទៅ, យើងយកចានរបស់យើងទៅដាកើអោយគេដួសបបរចែក។

ក៖ ចាសអ៊ុំ! អញ្ចឹងចាននឹងគែចែកអោយយើងដាច់ៗ?

ខ៖ ចាសនឹងហើយ។

ក៖ ចាស! ពេលដល់ម៉ោងយើងទៅយក?

ខ៖ ចាស! អញ្ចឹងឯង, ពេលដែលដល់ម៉ោងទៅយកអញ្ចឹងឯង។

ក៖ ចាសអ៊ុំ! អញ្ចឹងកាលនៅជំនាន់នឹងក្រៅពីជីកដីស្រែហីអ៊ុំ?

ខ៖ ចាស!ជីកដីស្រែស្ទូង ដក។

ក៖ ចាស! អញ្ចឹងតើអ៊ុំមានគេប្រើអោងយធ្វើអ្វីផ្សេងពីនឹងទៀតដែលឬអត់?

ខ៖ អត់ទេ! កាលនឹងអ៊ុំនៅក្មេងដែលគេអត់ប្រើ។ គេប្រើចែកតាមកងចល័យនឹងខាងយុវនារី អោយទៅធ្វើជីកប្រឡាយទឹក។

ក៖ ចាសអ៊ុំ។

ខ៖ មួយម៉ាក់ក៉ាអីចឹងទៅណាស់។

ក៖ ចាសអ៊ុំ។

ខ៖ អើ! គេអោយអ៊ុំទៅជីកដី ទៅជីកដី ទៅលើកប្រឡាំយនៅកន្លែងនឹងឯង។ល

ក៖ ចាសអ៊ុំ!។

ខ៖ ហើយនឹងស្ទូង!ដល់ពេលដកស្ទូងហើយចឹងទៅ។ យើងមកតាមភូមោមកដកស្ទូងបើតែបញ្ជូនទៅមុខទៅតែហៅថានារីទ័ពស្រួត។ ១៤ ១៥ឆ្នាំ ទ័ពស្រួច ហើយគេ១៧ ១៨ ២០។

ក៖ ទ័ពស្រួច ហាហា!

ខ៖ ចាស ជាមួយគេ ១៧ ១៨ ២០។ ហើយយើងប្អូនគេ។ អាយុតិចជាងគេហើយគេបញ្ជូនយ៉ង ទៅមុខនឹងតែដែល។

ក៖ ហ៊ឺម! ចាស។

ខ៖ ចាស!

ក៖ ចាស នឹងហើយអ៊ុំ។

ខ៖ នឹងហើយ! មានតែជីក ហើយនឹងទៅរ៉ែកដីតែប៉ុនន្នឹងឯងអត់មានទៅធ្វើអីទៀតទេ។

ក៖ ចាសអ៊ុំ! អញ្ចឹងនៅក្នុងចំនោមការងារទាំងអស់នឹងតើមួយណាដែលអ៊ុំគិតថាអ៊ុំពិបាកធ្វើជាំងគេ?

ខ៖ រែកដីនឹងស្នូងនឹងឯង។ គែអទ់មានប្រើយើងអោយទៅធ្វើការអៅផ្សេងទៀតទេ គេប្រើយើងតែពីរមុខនឹង។ កាលជំនាន់នោះដល់ពេលយើងរែកដីទៅជូនកាលយប់ទៅស្នូងម៉ោងបីអីនឹង។ គេផ្លុំកញ្ចែប្រែតត្រូវតែក្រោក។ ម៉ោងបួនអីនឹងឯង ទៅរែកដី។

ក៖ ចាសអ៊ុំ!

ខ៖ ទៅលើកដីម៉ោងបួនម៉ោងអីនឹងឯង ផ្លុំកញ្ចែប្រែតត្រូវតែងើប។

ក៖ ចាសអ៊ុំ! អូ! គេផ្លុំកញ្ចែតាមភូមៅឬក៏ម៉េចដែលអ៊ុំ?

ខ៖ គែមានកងចល័ត។

ក៖ អូ!! គេមានមេដឹកនាំ ពលព្រឹកឡើងគេ

ខ៖ គេផ្លុំកញ្ចែប្រែតចឹងទៅបើយើងក្រោកទាន់មិនទាន់គែទៅត្រូវនឹងទៀត។

ក៖ ចាស! បើក្រោកអត់ទាន់គែអោយយើងធ្វើអីដែលកាលនឹងអ៊ុំ?

ខ៖ គេបន្ថែមដូចថាគេវាស់ដីចឹងទៅ!បើយើងទៅគេវាស់ដូចយើងទៅយើតចឹងដូចថាកន្លះម៉ែ្រតគេបន្ថែមកន្លះម៉ែ្រតចឹងថែមទៀតទៅ។

ក៖ អូរ!!!

ខ៖ រែកទៀតទៅហើយគែដាក់ពិន័យយើងចឹងទៅ។

ក៖ អូ!!! ចាស។

ខ៖ អើ! ដល់ពេលយើងងើបទាន់ហើយអ៊ុំមិនដែលថាងើមមិនទាន់គែទេ។

ក៖ ទាន់រហូតហីអ៊ុំ។

ខ៖ លឿនរហូត។

ក៖ ចាសនឹង។

ខ៖ ខ្លាចតែថៃមមួយជាពីរនឹងហាស់, ហើយស្នងក៏ដោយមិនដែលហ៊ានថា! ខំប្រឹងធ្វើយ៉ាងម៉េចកុំអោយតែគេបន្ថែមមកទៀតធ្វើម៉េចខ្លាចវាទៅមិនរួច។ ទៅសុខចិត្តទៅអង្គុយងោក។

ក៖ ចាសអ៊ុំ!

ខ៖ អើ។

ក៖ នឹងអ៊ុំ! អញ្ចឹងពេលនឹងអ៊ុំបាននៅជុំឪពុកម្ដាយរបស់អ។មដែលឬអត់?

ខ៖ មានបានជុំឯណាបើគេបញ្ជូនទៅមុខអស់ហើយនឹង។ កងចល័ត។

ក៖ កងចល័តហីអ៊ុំ?

ខ៖ នឹងហើយ! នៅជុំនៅជុំតែក្មេងៗ ដូចថានៅតូចៗចឹងទៅតែអោយនៅជាមួយម៉ែអីទៅ។ ហើយអ៊ុំនេះរៀងធំជាងគេ គេបញ្ជូនទៅមុខអស់។

ក៖ ហ៊ឹម! អញ្ចឹងតើពេលនឹងអ៊ុំពិបាកដែលឬអត់ដោយសារតែពេលនឹងអ៊ុំបែកពីគ្រុមគ្រួសារហើយ ហើយទោធ្វើការម្នាក់ឯងទៀត?

ខ៖ ទៅនៅ កងចល័តដូចគេហៅថាកងល័តអីចឹងហាស់?

ក៖ ចាស!!

ខ៖ គេហៅថាកងចល័ត។

ក៖ ចាស!

ខ៖ វាចល័តសព្វគ្រប់ គេចល័តយើងទៅនេះទៅនោះ។ កងចល័តគេចល័តសព្វគ្រប់ហើយវាមិននៅនឹងកន្លែងទេ។

ក៖ ចាសអ៊ុំ!

ខ៖ នៅជំនាន់នឹងហ្ន។ បើកុមារ កុមារវានៅមួយកន្លែងវាមានកន្លែថរៀនកន្លែងអីចឹងហាស់?

ក៖ ចាសអ៊ុំ!

ខ៖ បើយើងអត់កុមារ យើងចូលដូចយើងចូលវនារីហើយ, គ្មានកន្លែងរៀនទេ យើងចល័តរហូត។

ក៖ ចាសអ៊ុំ!

ខ៖ ចង់កន្លែងណាពិបាលវេទនាខ្លាំង! ដូចថាទ័ពស្រួច កងចល័តទៅហើយ។

ក៖ ចាសអ៊ុំ!!

ខ៖ ចឹងឯង។

ក៖ ចាស!

ខ៖ គេអោយយើងចល័យគ្រប់កន្លែងនឹង។

ក៖ ចាស!

ខ៖ គេមិនអោយយើងនៅមួយកន្លែងទេ។

ក៖ ចាសអ៊ុំ! អញ្ចឹងក្នុងពេលនឹងអ៊ុំអត់ដែលបានជួបគ្រុមគ្រួសារឪពុកម្ដាយម៉ងហះ?

ខ៖ ជួបតើ។

ក៖ ទាល់តែផុតហីអ៊ុំ?

ខ៖ នឹងហើយ! ទាល់តែផុតបានមកជួបគ្នា។

ក៖ ចាស!

ខ៖ ទាល់តែឆ្នាំ ១៩៧៩ ទាល់តែគេរំដោះផុតបានបានមកជួបគ្នាវិញ។

ក៖ បានបានមកជួបគ្រុមគ្រួសារវិញ។

ខ៖ ចាសនឹងហើយ!

ខ៖ បីឆ្នាំ យូរ។

កៈ ចាស! អញ្ចឹងចេះតែរកគ្នាឃើញដែលដោយសារតែស័យនឹងមនុស្សច្រើនណាស់ហើយបែកគ្នាហើយមករកកូនចៅហើយឪពុកម្ដាយឃើញដែល?

ខៈ យើងអត់មានដូចថាទៅស្រុកណា, ដូចថានៅសខេត្តបាត់ដំបងចឹង?

កៈ ចាស!

ខៈ នៅតែខេត្តបាត់ដំបង។ នៅតែក្នុងខេត្តនឹចឯងអត់មានទៅខេត្តណាផ្សេងអីទៀតទេ។

កៈ អូ!!!

ខៈ ដូចថានៅកំពង់ធំចឹង, នៅកំពង់ធំ នៅសង្កាត់ណា ដូចថាសង្កាត់ដាំងសៅ, ឧទាហរណ៍ថាដីចនៅភូមិអូរដំបងយើងចុះ។

កៈ ចាស!

ខៈ ដូចថាមួយឃុំអូរដំបងចឹងនៅតែមួយឃុំចឹងទៅ។

កៈ ចាសអ៊ុំ!

ខៈ ហើយដូចថា ហើយឧទារហណ៍ថាមួយឃុំនឹង មួយឃុំយើងចឹងទៅ។

កៈ ចាសអ៊ុំ!

ខៈ ឃុំឯងណាអូរដំបងពីរមួយឃុំចឹងទៅ, ហើយអត់មានច្រលូកច្រឡំគ្នាទៃណាស់?

កៈ ចាសអ៊ុំ!

ខៈ ហាចឹងវមិនហត់នេះទេ, ដូចថាសង្កាត់ចឹងទៅ នៅជុំគ្នាមួយសង្កាត់ចឹងទៅ។ ហើយមួយសង្កាត់មិនតិចទេណា?

កៈ ចាសអ៊ុំ! ធំដែលនឹងហាស់មួយសង្កាត់ៗ។

ខៈ ចាស។ យើងនៅជុំគ្នាដល់ពេលចឹងទៅវាធំដែលនឹងហាស់។

កៈ ចាស!

ខ៖ ចុះយើងមិនហាត់ថារកផ្ទះមិនឃើញណា។

ក៖ ចាសអ៊ុំ!

ខ៖ នៅកងចល័តតាំងពី៧៥រហូតដល់៧៩ប៉ុន្មាន?

ក៖ ៧៥ រហូតដល់ ៧៩ហីអ៊ុំ?

ខ៖ ចាស!

ក៖ បួនឆ្នាំ!

ខ៖ ចាស! ហើយតាំងតែពីចូលភ្លាមចូលចល័យរហូត។

ក៖ ហ៊ឹម!

ខ៖ មិនមែននៅតែកន្លែងកុមារទេណាស់។ លើកតែដីស្ទូងតែស្រែរហូត។ រ៉ែកដីរហូត។

ក៖ ចាស! ធន់ៗរហូត។

ខ៖ ចាសធន់។

ក៖ ចាស! លើកតែដីហើយស្ទូងតែស្រូវ។

ខ៖ ចាស!

ក៖ នឹងអ៊ុំ! អញ្ចឹងអ៊ុំបានប្រាប់ខ្ញុំថាអ៊ុំមានកូនស្រីមួយនៅអាមេរិចមែណទេអ៊ុំ?

ខ៖ ចាសនឹងហើយ!

ក៖ អញ្ចឹងតើអ៊ុំមានសាច់ញ្ញាត្តិឬក៏បងប្អូនណាដែលនៅស្រុកក្រៅទៀតដែលឬអត់ក្រៅពីកូនរបស់អ៊ុំ?

ខ៖ ឯត់មានទេ!

ក៖ អត់មានទេន៍អ៊ុំ?

ខ៖ ចាស! អត់មានទេ។

ក៖ ចាស! អញ្ចឹងអ៊ុំអាចប្រាប់ពីជិវិតរបស់អ៊ុំពេលដែលធំឡើងតើអ៊ុំបានធំឡើងយ៉ាងដូចម៉េចដែល?

ខ៖ ធំ?

ក៖ តាំងពីក្មេងមករហូតដល់អ៊ុំពេគវ័យហាស់? ជីវភាពគ្រួសារពិបាកហើយវេទនាយ៉ាងម៉េចខ្លះ?

ខ៖ ជីវភាពពិបាកវេទនាណាស់។ ពីក្មេងមកហូ!! យើងជីវភាពរបស់យើងវាក្រសត់ហាស់។

ក៖ ចាស!

ខ៖ នឹងហើយ! ជីវភាពរបស់អ៊ុំនៅពេលនឹងដូចថាបើសិនជាអត់មាន! បើសិនជាក្រវិញគឺក្រជាំងគៃតែម្តង។

ក៖ ចាសអ៊ុំ!

ខ៖ នឹងហើយ! កាលដែលអ៊ុំធំដឹងក្តីមកអ៊ុំឃើញតែម្តាយអ៊ុំនឹងគាត់ក្រជាងគេ។ ខោអាវសំល្លៀកបំពាក់អី ប្រណាះពីរបីដូចថា ចាស់ៗពីដើមដឹងស្រាប់ហើយថា ត្រួតៗលើគ្នាដល់ពេលលើកឡើងធំតែប្រណះនឹងឯង។

ក៖ ចាសអ៊ុំ!

ខ៖ មិនដូចយើងសព្វថ្ងៃនេះទេ។ មិនថាយើងសព្វថ្ងៃនឹងនេះទេ, ប៉ុន្តែវាគ្រាន់។ វាគ្រាន់ជាងមុន។

ក៖ ចាសនឹងហើយអ៊ុំ!

ខ៖ បើថាពីក្មេងមកអ៊ុំវេទនាណាស់! ភ្ជួរស្រែនឹងក៏ភ្ជួរស្រែ ហើយដកស្ទូង។

ក៖ ចាស!

ខ៖ ចាស! ហើយភ្លូវផងព្រោះផង។ ចុះឪពុកខ្ញុំគាត់ស្លាប់តាំងពី៧៥នឹងមក។ យើងមិនចុះចូល យួនចូល៧៩នឹងមកយើងភ្លូវរហូតនោះ។

ក៖ ចាសអ៊ុំ!

ខ៖ ភ្លូវផងព្រោះផង ដកផង ស្ទូងផង។ បើចប្អូនៗនៅតូចៗ គឺនៅលើអ៊ុំទាំងអស់

ក៖ ចាសអ៊ុំ!

ខ៖ មកវិញចឹងទៅ ចំការទៀតទៅ។

ក៖ ចាស!

ខ៖ ហើយបើនិយាយពីកំសត់វេទនាគ្មានពីណាវេទនាដូច។

ក៖ ចាសអ៊ុំ!

ខ៖ ហើយរហូតមកដល់នេះទៀតដឹងស្រាប់ហើយ។ នៅតាមជ្រាយដែនទំរាំតែបាននៅសុខ ដល់សព្វថ្ងៃទឹមតែបានប្រហែលប៉ុន្មានឆ្នាំនេះនឹង។

ក៖ ចាស!

ខ៖ បើមិនអញ្ចឹងមិនធ្លាក់ដល់ថៃដល់ណាដល់ណីទេ។ ឈប់ទៅធ្វើចំការអោយម៉ែក្មួយឯងនៅ ទឹកពុះនឹង។

ក៖ ចាសអ៊ុំ!

ខ៖ អើ! រហូតដល់ថៃ, ប៉ុន្មានហើយ ពីរឆ្នាំនឹងតែដែល។

ក៖ ចាស!

ខ៖ ចង់ដាច់ខ្យល់! ទំរាំតែបាននៅសុខ សព្វថ្ងៃនឹងបាននៅសុខនៅនឹងផ្ទះតិចទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ពិបាកណាស់ វេទនាណាស់។ វេទនារហូត។

កៈ វេទនារហូតនេះអ៊ុំ?

ខៈ ចាស!

កៈ អញ្ចឹងជីវិតរបស់អ៊ុំឥឡូវនេះយ៉ាងម៉េចដែល?

ខៈ វាមានម៉េចទេ វាគ្រាន់បើជាងមុនតិចនឹងឯង។

កៈ តែបន្តិចទេន៏អ៊ុំ?

ខៈ ចាស! ផ្ទះអ៊ុំអត់មាននៅផងនឹង, អោយអ៊ុំថាមានខ្លាំងម៉េច។ មានយ៉ាងម៉េច?

កៈ អូ!! ចាសអញ្ចឹងសព្វថ្ងៃនេះនៅជាមួយអ្នកណាគេ?

ខៈ អ៊ុំនៅជាមួយម៉ែចិញ្ចឹមជាមួយយាយយឿត។ ជាមួយម៉ែចិញ្ចឹមតើ។

កៈ អូរ!!!

ខៈ ដីក៏អ៊ុំគ្មាននៅចាស!

កៈ ចាស!

ខៈ ផ្ទះក៏អ៊ុំគ្មាននៅ! អោយអ៊ុំថាគ្រាន់យ៉ាងម៉េច។

កៈ ចាសនឹងហើយអ៊ុំ!

ខៈ នឹងហើយ!

កៈ ចាសនឹងហើយអ៊ុំ! អញ្ចឹងបើប្រៀបធៀបពីសម័យមុខមកនឹងសម័យនេះតើវាខុសគ្នាយ៉ាងម៉េចដែល?

ខៈ យើងគ្រាន់បាននៅហូចចុកនៅផ្ទះ, អត់ហាត់ពិបាកទៅរ៉ែកដី ពិបាកធន់អីនឹងប៉ុននឹងឯង។

កៈ ចាស!! ឥឡូវនឹងយើងមានសេរីភាព។

ខៈ ចាស! ឥឡូវនេះយើងមានសេរីភាព។ ដូចថាអត់មានអ្នកណាដូចថាម៉ោងដប់ ១១ ២ ៣ អី គែផ្លុំកញ្ចែច្រែតអីគឺគ្មាន។

កៈ ចាសហាហស!

ខៈ នឹងហើយ។ ប៉ុន្តែបើថាជីវភាពរស់នៅវាគ្រាន់ដែល។ ដូចថាទឹមតែប្រើសៗតិចហាស់ វាមិនសូវហត់ដូចមុន។

កៈ ចាស!

ខៈ ដល់ពេលចាស់ហើយ! បើពីមុខមកអ៊ុំវេទនាតែរហូតនឹង។

កៈ ចាសអ៊ុំ!

ខៈ ស៊ីឈ្នួលដកស្ទូងគេតែរហូត។ ធ្វើស្រែចំការអោយគេ។

កៈ ចាស!

ខៈ ទៅអូរកាច់អូរអីធ្លាក់កាឡុកធ្លាក់អីណាណី។ ហាហា!

កៈ ទៅអស់ហើយន៍អ៊ុំ? ឆ្មៃងកាត់អស់ហើយ។

ខៈ ចាសទៅអស់ហើយ។ កាប់ដំឡូង។ ដាំសណ្តែក, ស៊ីឈ្នួលគេមួយថ្ងៃប្រាំពាន់ប្រឹងចង់ងាប់។ ហាហ!

កៈ ចាស! មួយថ្ងៃបានតែប្រាំពាន់តែអ៊ុំ?

ខៈ ចាស! សួរម៉ែនាងឯងទៅ។ មួយថ្ងៃបានតែប្រាំពាន់នឹង។ ថ្លៃផងកាលនឹងហ្វ!!!

កៈ ថ្លៃមែណទែន។

ខៈ ចាស! ហើយថ្លៃផងកាលនឹងហ្វ!

កៈ ចាសអ៊ុំ!

ខៈ គេបួនពាន់បីពាន់។ បីពាន់បួនពាន់។

កៈ ចាស!មួយថ្ងៃប្រាំពាន់នឹងធ្វើពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែលអ៊ុំ?

ខៈ ធ្វើពីម៉ោងប្រាំពីរដល់ម៉ោង១១។

កៈ ចាស!

ខៈ ជូនណាទៅម៉ោងប្រាំមួយ ហើយជូនណាប្រាំមួយកន្លះអីចឹងទៅ។

កៈ ចាសអ៊ុំ!

ខៈ ម៉ោង១១ ១១ ជាងអៅចឹងទៅ។

កៈ ចាសអ៊ុំ! អញ្ចឹងធ្វើតែមួយព្រឹកៗតើហីអ៊ុំ?

ខៈ អតទេមួយថ្ងៃហាស់។

កៈ ដល់ពេលល្ងាចទៀតហះ?

ខៈ ចាសនឹង!

កៈ អញ្ចឹងពេលល្ងាចចូលធ្វើការពីម៉ោងប៉ុន្មាន?

ខៈ ម៉ោង១២:៣០ ជួនណាទៅម៉ោងមួយអីទៅ។

កៈ ចាស!

ខៈ ជូនកាលម៉ោងមួយមិនដល់ផង។

កៈ ចាស!

ខៈ តែបាយហើយនឹង។ និយាយថាពីប្រផាត់ចាប់ប្រផឹងទៀតហ៉ាយ។

កៈ ចាស! ហាហា។

ខៈ ហាហាហ! អើ!

កៈ តើអ៊ុំចង់ចង់ទៅធ្វើចំការអញ្ចឹងទៀតដែលឬអត់?

ខៈ ទៅធ្វើចំការចឹងវាទៅមិនរួចទៀតនឹងណាស់។

កៈ ទៅលេងរួចហើយន៍អ៊ុំ?

ខ៖ ចាសវាឈឺជង្គន់។ អង្គុយយូរងើបឡើងជាប់។ ចំការនៅក្រោយផ្ទះមិនទាន់បានធ្វើស្មៅផង។

ក៖ ចាសអ៊ុំ! អញ្ចឹងអ៊ុំតើអ៊ុំបានទៅរៀនដែលដែលអ៊ុំនៅពីក្មេង?

ខ៖ មិនបានចូលសាលារៀនទេ! ចូលបានមាណថ្នាក់ទីមួយទីពីរនឹង។

ក៖ អ៊ុំបានថ្នាក់ទីមួយទីពីរដែលហ្ន?

ខ៖ ចាស!

ក៖ ចាស!

ខ៖ រៀនមិនចេះទេ! មិនចេះអក្សរអីទេ។

ក៖ ចាសអ៊ុំ!

ខ៖ មិចេះអក្សរទេ។

ក៖ ឯញ្ចឹងតើអ៊ុំចេះមើលអក្សរដែលឬអត់?

ខ៖ មិនចេះទេមើលបានតែឈ្មោះខ្លួនឯងតិចៗ។

ក៖ អ៊ុំចេះមើលឈ្មោះខ្លួនឯងហ្ន?

ខ៖ ចាស!

ក៖ ហាហា!

ខ៖ មើលបានតែឈ្មោះខ្លួនឯង ចេះសរសេរតែឈ្មោះខ្លួនឯង។

ក៖ អាណឹងល្អហើយកុំអោយតែយើងអត់ចេះសរសេរឈ្មោះខ្លួនឯងទៀត។

ខ៖ ចាស!!

ក៖ ចាស! អញ្ចឹងក្រៅធ្វើការតើអ៊ុំមានស្រែចំការធ្វើនឹងគេអត់អ៊ុំ?

ខ៖ អត់មានទេ!

ក៖ អត់មានទេន៍អ៊ុំ។

ខ៖ អត់មានទេ! អត៎ោមានដីចំការដីអីទាំងអស់។

ក៖ ចាស!

ខ៖ ថាស្អីក័អត់ដែលអ៊ុំហ្វ។

ក៖ ចាសអ៊ុំ! ផ្ទះក៏អត់មានដែលអ៊ុំន៍?

ខ៖ ចាស! ផ្ទះក៏ណៅជាមួយគេ។ ម៉ែក្មួយឯងដឹងស្រាប់នៅ។

ក៖ ចាសអ៊ុំ!

ខ៖ដីយើងវាគ្មាននៅយើងនីជាមួយគេ។

ក៖ ចាស! អញ្ចឹងក្រៅពីការងារដើរស៊ីឈ្នួលអោយគេបាស់? តើអ៊ុំមានមុចរបរអីខ្លួនឯងដែល ឬអត់? រកស៊ីអី?

ខ៖ អត់!

ក៖ អត់ទេន៍អ៊ុំ?

ខ៖ ឯត់ពីស៊ីឈ្នួលគេនៅតែចឹងឯង។

ក៖ ចាស!

ខ៖ ធ្វើចំការស្មៅនៅនឹងក្រោយផ្ទះតិចៗនឹងទៅ។ ដីចំការយាយនឹង។ ហើយរវល់តែធ្វើកូរផែន ស្វាយចំការដុះស្មៅឡើងស្គុក។

ក៖ ចាសអ៊ុំ!

ខ៖ ចាស!

ក៖ អញ្ចឹងតើឥឡូវនេះតើអ៊ុំធ្វើការងារអ្វីដែល?

ខ៖ នៅតែផ្ទះ។

ក៖ ចឹងនៅតែផ្ទះតែន៍អ៊ុំ?

ខ៖ ចាសនឹងហើយនៅតែផ្ទះ។

ក៖ ចាស!

ខ៖ ធម្មតានៅធ្វើស្មៅចំការនៅក្រោយតិចៗទៅ។

ក៖ ចាស!

ខ៖ នឹងហើយ!

ក៖ ចាស! អញ្ចឹងកាលដែលអ៊ុំនៅពីក្មេងហាស់? តើជីវភាពគ្រុមគ្រួសាររបស់អ៊ុំយ៉ាងម៉េចដែលជីវផាពការរស់នៅហាស់?

ខ៖ អ៊ុំថាវេទនាណាស់។

ក៖ ចាស!

ខ៖ ពីក្មេងមកវេទនាណាស់, ម៉ែឪគាត់ក្រ។ ម៉ែ!

ក៖ ចាស!

ខ៖ មិនឮអ៊ុំថា! តាំងពីនិយាយពីថាវេទនាថាគ្មានអ្នកណាពិបាកដល់នឹកឃើញ។ ក្រសត់។

ក៖ ចាសអ៊ុំ!!

ខ៖ តាំងពីអ៊ុំធំដឹងក្ដីមក មកឮសូរអ៊ុំថាទេ សំពត់ខោអាវអី។ បើនិយាយពីថាប្រណះវិញមិនដឹងថាជាប៉ុន្មានជាន់ទេ។

ក៖ ចាសអ៊ុំ!

ខ៖មិនដែលថាមានស្អីស្លៀកសមរ្យនឹងគេហាស់។

ក៖ ចាសនឹងហើយអ៊ុំ។

ខ៖ ចាស!

ក៖ អញ្ចឹងឪពុកម្ដាយរបស់អ៊ុំហើយនឹងបងប្អូនរបស់អ៊ុំតើមានអ្នកណាម្នាក់ដែលគាត់ចេះធ្វើអីមួយដែលជាជុងជំនាញផ្ទាល់ខ្លួនខាងអ្វីមួយទេអ៊ុំ?

ខ៖ ធ្វើតែចំការ។

ក៖ ធ្វើតែចំការមួយទេន៍អ៊ុំ?

ខ៖ ចាសធ្វើតែចំការ! ស្រែនឹងរហូតហាហាហ!

ក៖ ចាស! ហើយដល់ពេលឥឡូវនេះនៅតែធ្វើស្រែចំការនឹងទៀត?

ខ៖ ចាស! នៅតែចំការស្រែ។ ដូចថារៀនទៅវាអត់ចេះអីមួយ។ ដល់ពេលដែលរៀនអត់ចេះចឹងទៅមានតែធ្វើការចំការស្រែចឹងទៅ។

ក៖ ចាសអ៊ុំ!

ខ៖ មានតែស្រែមានចំការចឹងទៅ។ មានតែស្រែហើយនឹងចំការតែប៉ុននឹងឯង។

ក៖ ចាសអ៊ុំ!

ខ៖ ចាស!

ក៖ ចាស! អស់ពីចំាករដល់ស្រែ ហើយអស់ពីស្រែដល់ចំការ។

ខ៖ ចាសនឹងហើយ! វិលជុំ

ក៖ វិលជុំអ៊ុំនេះ?

ខ៖ ចាស!

ក៖ អញ្ចឹងតើអ៊ុំអាចប្រាប់ខ្ញុំបានទេ! ថាតើពេលវេលាណាដែលអ៊ុំគិតថាពុបាកជាំងគេនៅក្នុងជីវិតរបស់អ៊ុំហាស់? ហើយតើអ៊ុំបានឆ្លងកាត់វាបាកដោយរប្រៀបណា? ដោយសារតែខ្ញុំបានដឹងហើយថាអ៊ុំបានឆ្លងកាត់នូវការលំបាកជាច្រើន ចឹងមួយណាដែលធំលំបាកជាងគេ?

ខ៖ ពិបាកដែលនឹងមិនអាចថានិយាយថាយ៉ាងណាហះ! និយាយថាវាមិនដឹងថាវាពិបាក?

ក៖ រើសយកមួយមកនិយាយមកអ៊ុំ។

ខ៖ និយាយថាពិវាបាកគឺពិបាកមែនទែន។ពិបាកដូចថា យើងធ្វើតាំងពីយើងធំដឹងក្ដីមកធ្វើឪផងធ្វើបងផង អីចឹងហាស់?

ក៖ ចាសអ៊ុំ!

ខ៖ នឹងហើយ! ដូចថានៅក្នុងការងារប្រុសអីចឹងគឺនៅលើយើងទាំងអស់អីអញ្ចឹងហាស់?

ក៖ ចាសអ៊ុំ។

ខ៖ បើម៉ែខ្ញុំគាត់មេម៉ាយហើយខ្ញុំបងគេ, យើងជូនការផ្ទះជូនកាលត្រូវឡើងប្រក់ ប្រក់។

ក៖ ចាស!!

ខ៖ ហើយត្រូវវាយជញ្ជាំងវាយជញ្ជាំង។

ក៖ ចាស!

ខ៖ អ៊ុំ! ផ្ទះស្លឹងដូងចេះចេះអី, កុំថាអ៊ុំធ្វើមិនកើតអ៊ុំធ្វើកើតទាំងអស់។

ក៖ ចាសអ៊ុំ!

ខ៖ ត្រូវឡើងប្រក់ផ្ទះ, ឡើងប្រក់ក្ដែត។

ក៖ ចាស!

ខ៖ ក្បឿងក៏ចេះប្រក់ហើយស្បូវក៏ចេះប្រក់។

ក៖ ចាសអ៊ុំ!

ខ៖ និយាយពីថាការងារមនុស្សប្រុសអ៊ុំអត់?

ក៖ ចេះតាំងអស់?

ខ៖ ចាស! អ៊ុំអត់ចេះមួយឡើងត្នោតអ៊ុំអត់ចេះឡើងនឹងគេទេ។

ក៖ ចាសអ៊ុំ!

ខ៖ ចាស! ហើយបើថាប្រវែងប៉ុននេះអ៊ុំឡើងរួច។

ក៖ ចាសអ៊ុំ!

ខ៖ បីក្មេងហាស់?

ក៖ ចាស!

ខ៖ តែដល់ពេលឥឡូវនេះអ៊ុំធ្វើលែងរួចហើយ។

ក៖ ចាស! ឥឡូវអ៊ុំធ្វើលែងរួចហើយន៏?

ខ៖ ចាស!

ក៖ ចាស! ខ្ញុំកំពុងគិតថាចង់បានអ៊ុំទៅប្រក់តំបូលផ្ទះអោយ។

ខ៖ ហាហា!

ក៖ ចាស! និយាយលែងទេអ៊ុំ។ ហាហា! អ៊ុំថាឥឡូវអ៊ុំឡើងលែងរួចហើយ។

ខ៖ ឡើងលែងរួចហើយ។

ក៖ ហាហាហា ចាស! អញ្ចឹងក្រៅពីការលំបាកអ្វីទាំងអស់នឹងហើយ។ តើអ៊ុំមានពេលវេលាណាដែលអ៊ុំកិតថាសប្បាយរីករាយនៅក្នុងជីវិតរបស់អ៊ុំដែលឬទេ?

ខ៖ ពីពេលសប្បាយទើមតែពេលមកឥឡូវនេះទេ។ បានសប្បាយគ្រាន់បន្តិច។

ក៖ ចាសអ៊ុំ!

ខ៖ ពេលចាស់រៀងគ្រាន់បានសប្បាយចិត្ត។

ក៖ ចាសអ៊ុំ!

ខ៖ ចាស!

ក៖ អញ្ចឹងទើបតែបានប៉ុន្មានឆ្នាំនេះដែលមែនដែលតែអ៊ុំ?

ខ៖ ចាសនឹងហើយ! ទើបតែបានពីរបីឆ្នាំនេះទេ។

ក៖ ចាស! អញ្ចឹងកាលពីពេលដែលអ៊ុំមានគ្រុមគ្រួសារមានកូនតើបេលនឹងតើអ៊ុំសប្បាយចិត្ត ដែលឬអត់?

ខ៖ ចាស!ពេលបានមានគ្រុមគ្រួសារហើ?ទោះបីជាមានក៏គែដូចថាយើងបែកគ្នាគែទៅធ្វើទាំហានទៅហើយគេទុកយើងចោលនៅតែឯងទៅ។

ក៖ ចាសអ៊ុំ!

ខ៖ វាដូចជាមិានសូវ?

ក៖ មិនសូវសប្បាយន៍អ៊ុំ?

ខ៖ ចាសនឹងហើយ។

ក៖ ចាស! អញ្ចឹងតើជីវិតរបស់អ៊ុំទៅថ្ងៃខាងមុខទៀតតើអ៊ុំរំពឹងហើយចង់បានអ្វី?

ខ៖ ទៅខាងមុចទៀត! មិនដឹងថារំបឹចចង់បានស្អីទៀតទេ។ ដូចថារំពឹងទៅលែងរួចហើយ។

ក៖ ចាស!

ខ៖ វាមិនផាចទៅបានហាស់? ដោយសារតែយើងវាចំណាស់នេះទៅហើយហាស់?

ក៖ ចាសអ៊ុំ!

ខ៖ ទោះបីបើថាយើងរំពឹងចង់បានអ្វីមួយក័យើងទៅអត់រួច។

ក៖ ចាស! ដូចថាអាយុយើងចាស់ហើយ!

ខ៖ ចាស! អាយុថា៦០ឆ្នាំចុះ។

ក៖ ចាសនឹងហើយអ៊ុំ។ អញ្ចឹងជូនពរអ៊ុំអោយជីវិតរបស់អ៊ុំសង្ឃឹមថាទៅមុខទៀតបានសុខស្រួយហើយឈប់វេទនាទៀត។

ខ៖ ចាសចាសសាធូបសាធូប។

ក៖ ចាស! អញ្ចឹងតើអ៊ុំមានធ្វីទៀតដែលរទេដែលអ៊ុមចង់ប្រាប់មកខ្ញុំ?

ខ៖ ដូចថាមិនមានអ្វីទៀតទេ។

ក៖ អស់ហើយន៍អ៊ុំ?

ខ៖ ចាស! នឹងហើយ។

ក៖ អញ្ចឹងខ្ញុំក៏អស់អ្វីសួរដែល។

ខ៖ ចាសហាហា!

ក៖ អញ្ចឹងខ្ញុំសូមអរគុណអ៊ុមច្រើនដែលបានចំណាយពេលវេលាអោយខ្ញុំធ្វើការសម្ភាសអ៊ុំនៅថ្ងៃនេះ។

ខ៖ ចាសះរគុណច្រើន។

ក៖ ខ្ញុំសូមថតរូបអ៊ុំមួយបានដែលអត់ពីមុននឹងចប់ទៅ?

ខ៖ ចាសបាន!

ក៖ អរគុណច្រើនអ៊ុំ៕